**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០៤៤......សហវ.គ.ស.ស.អ.គ.ក

**SOCIAL PROTECTION IN CAMBODIA**

# សេចក្តីសម្រេច
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទីខែ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រការឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជាក្រឹត្យលេខ នស/រកត/០៦១៧/៤៤៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia
nspc.gov.kh / t.me/socialprotectionkh
ទូរសព្ទលេខ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone : (+855) 23 890 666
gs_nspc@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២ ស្តីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម
- យោងតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

សេចក្តីសម្រេចនេះ មានគោលបំណងកំណត់អំពីមុខងារ និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម សរសេរអក្សរកាត់ថា **អ.ក.គ.** ដើម្បីគាំទ្រដល់ការបំពេញមុខងាររបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម, គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម និងនិយ័តករសន្តិសុខសង្គម។

**ប្រការ២.-**

សេចក្តីសម្រេចនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋាន។

## ជំពូក២

## មុខងារ និងភារកិច្ច

**ប្រការ៣.-**

អ.ក.គ. បំពេញមុខងារជាសេនាធិការគោលនយោបាយ និងបច្ចេកទេស របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម, គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម ព្រមទាំងបំពេញមុខងារនិយ័តករសន្តិសុខសង្គម។

**ប្រការ៤.-**

អ.ក.គ. មានមុខងារ និងភារកិច្ច ដូចខាងក្រោម៖

- ទ្រទ្រង់កិច្ចដំណើរការរបស់គណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម រួមទាំងការងាររៀបចំតាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គមនៅក្នុងប្រព័ន្ធគាំពារសង្គម
- រៀបចំឯកសារ របាយការណ៍កិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម និងគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- ផ្តល់យោបល់ និងលើកសំណើជូនក្រុមប្រឹក្សាជាតិគាំពារសង្គម និងគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម លើជំនាញបច្ចេកទេស និងគោលនយោបាយ ព្រមទាំងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងកិច្ចគាំពារសង្គម។

- សហការ និងសម្របសម្រួលជាមួយអនុគណៈកម្មាធិការ ក្រុមការងារបច្ចេកទេស ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងស្ថាប័នឯកជន ក្នុងការជំរុញការអនុវត្តគោលនយោបាយគាំពារសង្គម
- អនុវត្តយន្តការតាមដាន និងត្រួតពិនិត្យ លើការអនុវត្តគោលនយោបាយគាំពារសង្គម ដើម្បីធានាតម្លាភាព និងគណនេយ្យភាព
- រៀបចំ និងអនុវត្តបទប្បញ្ញត្តិ ស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធសន្តិសុខសង្គម ដែលដាក់ចេញដោយក្រុមប្រឹក្សាជាតិគាំពារសង្គម
- តាមដាន វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបានគាំពារសង្គម ដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ និងក្រុមប្រឹក្សាជាតិគាំពារសង្គម ពិនិត្យ និងសម្រេច
- រៀបចំផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម
- រៀបចំគម្រោងថវិកា និងគ្រប់គ្រងថវិការបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម ស្របតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមសម្រាប់ការអនុវត្តគោលនយោបាយគាំពារសង្គម
- រៀបចំ ផ្សព្វផ្សាយ និងលើកកម្ពស់ចំណេះដឹងជាសាធារណៈ អំពីគោលនយោបាយជាតិគាំពារសង្គម
- បំពេញមុខងារនិយ័តករសន្តិសុខសង្គម
- បំពេញការងារផ្សេងទៀតតាមការកំណត់របស់គណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម

## ជំពូក៣
## នាយកដ្ឋានជំនួយសង្គម

**ប្រការ៥.-**

នាយកដ្ឋានជំនួយសង្គមបំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារជំនួយសង្គមដូចខាងក្រោម÷

- ផ្តល់យោបល់លើរាល់សំណើគោលនយោបាយនានាដែលពាក់ព័ន្ធនឹងប្រព័ន្ធជំនួយសង្គម
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តកម្មវិធីជំនួយសង្គមនានាឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់
- អនុវត្តការងារតាមដាន និងត្រួតពិនិត្យដំណើរការអនុវត្តកម្មវិធីជំនួយសង្គមទាំងអស់ដើម្បីរាយការណ៍ជូនអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម
- រៀបចំលក្ខខណ្ឌតម្រូវ និងស្តង់ដារនៃរបាយការណ៍នានាសម្រាប់ប្រតិបត្តិករជំនួយសង្គម ដាក់ជូនក្រុមប្រឹក្សាជាតិគាំពារសង្គមពិនិត្យ និងអនុម័ត
- ពិនិត្យ និងផ្តល់យោបល់លើសំណើគម្រោងថវិកានានាពាក់ព័ន្ធនឹងកម្មវិធីជំនួយសង្គម តាមការចង្អុលបង្ហាញ ពីអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម និង
- អនុវត្តការងារផ្សេងៗទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូក៤
## នាយកដ្ឋានសន្តិសុខសង្គម

**ប្រការ៦.-**

នាយកដ្ឋានសន្តិសុខសង្គម បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានលើការងារសន្តិសុខសង្គម ដូចខាងក្រោម÷

- ផ្តល់យោបល់លើរាល់សំណើគោលនយោបាយនានាដែលពាក់ព័ន្ធនឹងប្រព័ន្ធសន្តិសុខសង្គម
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តរបបសន្តិសុខសង្គមនានាឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់
- អនុវត្តការងារតាមដាន និងត្រួតពិនិត្យដំណើរការអនុវត្តរបបសន្តិសុខសង្គមទាំងអស់ ដើម្បីរាយការណ៍ជូនអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម
- រៀបចំលក្ខខណ្ឌតម្រូវ និងស្តង់ដារនៃរបាយការណ៍នានា សម្រាប់ប្រតិបត្តិករសន្តិសុខសង្គម
- ផ្តល់យោបល់លើរាល់សំណើគម្រោងថវិកាពាក់ព័ន្ធនឹងរបបសន្តិសុខសង្គម
- អនុវត្តការងារផ្សេងៗទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៥
## នាយកដ្ឋានត្រួតពិនិត្យ

**ប្រការ៧.-**

នាយកដ្ឋានត្រួតពិនិត្យ ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន បំពេញមុខងារ និងភារកិច្ច ដូចខាងក្រោម÷

- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រតិបត្តិការនៃរបបសន្តិសុខសង្គម រួមមានផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ ផ្នែកប្រាក់សោធន និងផ្នែកនិកម្មភាពការងារ និងរបបថែទាំសុខភាពផ្សេងទៀត រួមទាំងប្រតិបត្តិការពាក់ព័ន្ធ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន
- ត្រួតពិនិត្យការចុះកិច្ចព្រមព្រៀងរវាងប្រតិបត្តិករសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលឯកជន និងវាយតម្លៃអនុលោមភាពនៃកិច្ចព្រមព្រាងមូលដ្ឋានសុខាភិបាលឯកជនដែលចុះកិច្ចព្រមព្រៀង និងប្រតិបត្តិករសន្តិសុខសង្គម
- ត្រួតពិនិត្យ តាមដាន វិភាគ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិករសន្តិសុខសង្គម
- ត្រួតពិនិត្យប្រតិបត្តិករសន្តិសុខសង្គម និងតួអង្គពាក់ព័ន្ធ ដល់ទីកន្លែងជាប្រចាំ ឬតាមការចាំបាច់
- ត្រួតពិនិត្យ និងផ្តល់យោបល់លើការគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គមរបស់ប្រតិបត្តិករសន្តិសុខសង្គម អនុលោមតាមអនុក្រឹត្យស្តីពីគោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម និងបទប្បញ្ញត្តិពាក់ព័ន្ធ
- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់គ្រប់គ្រងប្រតិបត្តិករសន្តិសុខសង្គម និងតួអង្គពាក់ព័ន្ធ តាមការចាំបាច់
- ចូលរួមពង្រឹងការយល់ដឹង និងទំនុកចិត្តរបស់សាធារណជន លើប្រព័ន្ធសន្តិសុខសង្គម
- ផ្តល់យោបល់លើវិធានការដែលត្រូវអនុវត្តចំពោះអំពើល្មើសធ្ងន់ធ្ងរទៅនឹងបទប្បញ្ញត្តិ តាមការចាំបាច់
- បំពេញមុខងារបន្ថែមជាលេខាធិការដ្ឋាននៃនិយ័តករសន្តិសុខសង្គម
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៦
## នាយកដ្ឋានផ្សះផ្សាវិវាទ និងការពារអ្នកទទួលផល

**ប្រការ៨.-**

នាយកដ្ឋានផ្សះផ្សាវិវាទ និងការពារអ្នកទទួលផល ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម លើការងារផ្សះផ្សាវិវាទ និងការពារអ្នកទទួលផល ដូចខាងក្រោម÷

- រៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងយន្តការនៃការផ្សះផ្សា និងការដោះស្រាយវិវាទក្នុងប្រព័ន្ធគាំពារសង្គម
- រៀបចំសេចក្តីណែនាំ និងលិខិតស្នាមផ្សេងៗពាក់ព័ន្ធនឹងការដាក់ពាក្យបណ្តឹង ការផ្សះផ្សា និងការដោះស្រាយវិវាទក្នុងប្រព័ន្ធគាំពារសង្គម
- ទទួលពាក្យបណ្តឹង រៀបចំ និង/ឬចូលរួមការផ្សះផ្សា/ការដោះស្រាយវិវាទក្នុងប្រព័ន្ធគាំពារសង្គម
- ប្រមូល និងចងក្រងរាល់សំណុំរឿងវិវាទ បណ្តឹង កំណត់ហេតុផ្សះផ្សា និងសេចក្តីសម្រេចនៃការដោះស្រាយវិវាទក្នុងវិស័យគាំពារសង្គម
- រៀបចំយុទ្ធសាស្ត្រ និងនីតិវិធីនៃកិច្ចការពារអ្នកទទួលផលក្នុងប្រព័ន្ធគាំពារសង្គម
- អនុវត្តផែនការសកម្មភាពពាក់ព័ន្ធនឹងកិច្ចការពារអ្នកទទួលផលក្នុងប្រព័ន្ធគាំពារសង្គម
- ចុះធ្វើការតាមដានពីការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនានា ព្រមទាំងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ដើម្បីការពារនូវសិទ្ធិអ្នកទទួលផល
- សម្របសម្រួល និងអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម
- ចូលរួមផ្សព្វផ្សាយព័ត៌មានពីកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលបាន និងកំពុងអនុវត្តដល់អ្នកទទួលផលក្នុងប្រព័ន្ធគាំពារសង្គម
- ចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៧
## នាយកដ្ឋានកិច្ចការទូទៅ

**ប្រការ៩.-**

នាយកដ្ឋានកិច្ចការទូទៅ ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន បំពេញមុខងារគាំទ្រ ដូចខាងក្រោម÷

- រៀបចំ និងកត់ត្រារាល់កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម
- សម្របសម្រួលជាមួយនាយកដ្ឋានពាក់ព័ន្ធ រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា
- សហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នអនុវត្ត ដើម្បីធ្វើការពង្រីកការយល់ដឹងអំពីប្រព័ន្ធគាំពារសង្គមនៅកម្ពុជា
- ផ្តល់ការគាំទ្រដល់កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងនិយ័តករសន្តិសុខសង្គម

- គ្រប់គ្រង តាមដានការងាររដ្ឋបាលនិងហិរញ្ញវត្ថុ និងគ្រប់គ្រងបុគ្គលិករបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងនិយ័តករសន្តិសុខសង្គម
- សម្របសម្រួលការងាររៀបចំផែនការសកម្មភាព និងគម្រោងថវិការបស់អគ្គលេខាធិការដ្ឋាន និងនិយ័តករសន្តិសុខសង្គម
- គ្រប់គ្រងត្រួតពិនិត្យ និងជួសជុលសន្ទិធិ និងសម្ភារៈបរិក្ខាររបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងនិយ័តករសន្តិសុខសង្គម
- រៀបចំដាក់ឱ្យដំណើរការ និងគ្រប់គ្រងគេហទំព័ររបស់អគ្គលេខាធិការដ្ឋាន និងនិយ័តករសន្តិសុខសង្គម
- រៀបចំ និងសរុបរបាយការណ៍ប្រចាំគ្រាជូនគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម និង
- អនុវត្តការងារផ្សេងៗទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ១០.-**

សេចក្តីសម្រេចលេខ ០០៣ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ